រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

# អនុក្រឹត្យលេខ ១៧ អនក្រ
# ស្តីពីការប្តូរឈ្មោះស្រុក ទីរួមខេត្ត សង្កាត់ក្នុងខេត្តបន្ទាយមានជ័យ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃ ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- តាមសំណើសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានប្តូរឈ្មោះស្រុក សិរីសោភ័ណ មកជា ស្រុក អូរជ្រៅ ដែលមានទីតាំងរដ្ឋបាលសាលាស្រុក អូរជ្រៅ តាំងនៅភូមិគីឡូលេខ ៤ ឃុំ ប៉ោយប៉ែត ។

**មាត្រា ២ :** ត្រូវបានប្តូរឈ្មោះ ទីរួមខេត្តរបស់ខេត្តបន្ទាយមានជ័យ មកជាស្រុកសិរីសោភ័ណ ដែលមានទីតាំងរដ្ឋបាល សាលាស្រុក នៅភូមិ កំពង់ស្វាយ ឃុំ កំពង់ស្វាយ ។

**មាត្រា ៣ :** ត្រូវបានប្តូរឈ្មោះ សង្កាត់ចំនួន ប្រាំបី ចំណុះទីរួមខេត្ត មកជា ឃុំ ចំនួន ប្រាំបី ចំណុះស្រុក សិរីសោភ័ណ គឺ ៖

១-សង្កាត់ ម្កាក់ មកជា ឃុំ ម្កាក់

២-សង្កាត់ ប៉ុស្បូវ មកជា ឃុំ ប៉ុស្បូវ

៣-សង្កាត់ ភ្នៀត មកជា ឃុំ ភ្នៀត

៤-សង្កាត់ ទឹកថ្លា មកជា ឃុំ ទឹកថ្លា

៥-សង្កាត់ អូរអំបិល មកជា ឃុំ អូរអំបិល

៦-សង្កាត់ ព្រះពន្លា មកជា ឃុំ ព្រះពន្លា

៧-សង្កាត់ កំពង់ស្វាយ មកជា ឃុំ កំពង់ស្វាយ

www.pheakdeylaw.com

៨_សង្កាត់ កោះពងសត្វ មកជា ឃុំ កោះពងសត្វ ។

**មាត្រា ៤ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត បន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ។

**មាត្រា ៦ :** អនុក្រឹត្យនេះមានអានុភាពអនុវត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ១៨ អនក្រ
## ស្តីពីការប្តូរឈ្មោះទីរួមខេត្ត សង្កាត់ ឃុំ ក្នុងខេត្ត កំពង់ឆ្នាំង

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១ :** ត្រូវបានប្តូរឈ្មោះទីរួមខេត្ត របស់ខេត្ត កំពង់ឆ្នាំង មកជាស្រុក កំពង់ឆ្នាំង ដែលមានទីតាំងរដ្ឋបាលសាលាស្រុក នៅភូមិស្រែត្រាំង ឃុំ កំពង់ឆ្នាំង ។

**មាត្រា ២ :** ត្រូវបានប្តូរឈ្មោះសង្កាត់ ចំនួន បួន ចំណុះទីរួមខេត្ត មកជា ឃុំ ចំនួន បួន ចំណុះស្រុក កំពង់ឆ្នាំងគឺ ÷

www.pheakdeylaw.com